# រពាក់និងប្រយោជន៍ក្នុងហត្ថកម្ម

រពាក់ឬនិយាយរត់មាត់ថា "ល្ពាក់" គឺជាពពួករុក្ខជាតិវល្លិតូចៗ មានបន្ទាល្អិតៗ មានផ្លែទុំហូបបាន។ នៅក្នុងចំណាត់ថ្នាក់រុក្ខជាតិ គេចាត់ទុករពាក់ក្នុងសន្តានពពួកផ្ដៅ តែវាមានដើមតូចជាងផ្ដៅ មានប្រវែងជាមធ្យមប្រហែល២ ទៅ៤ម៉ែត្រ។ ជាទូទៅរពាក់ដុះនៅដំបូក គម្លោត ឬដុបព្រៃតូចៗតាមវាលស្រែតំបន់ទំនាប ឬជាប់មាត់ព្រៃរបោះ(រូបលេខ១)។ ក្នុងសង្គមខ្មែរគេយកដើមរពាក់ប្រើជាប្រយោជន៍បានយ៉ាងច្រើនដូចជា ធ្វើខ្នួច ឬចំណង[1] ឬជាពិសេសប្រើក្នុងការងារហត្ថកម្ម ត្បាញ វេញ ឬក្រងតាមចំណោះរៀងៗខ្លួន ឱ្យកើតបានជាវត្ថុប្រើប្រាស់ផ្សេងៗមានជាអាទិ ដាល ត្រុក បង្គី ឈ្នាង វត្ថុតាំងលម្អផ្ទះ និងប្រើជាផ្នែកខ្លះនៃគ្រឿងសង្ហារិមជាដើម។ វត្ថុកើតចេញពីរពាក់ទាំងអស់នេះ គឺជាចំណែកយ៉ាងសំខាន់ក្នុងចំណូលគ្រួសាររបស់អ្នកស្រុក ក្រៅពីការងារស្រែចម្ការ។ ប៉ុន្តែបច្ចុប្បន្ន កត្តាបរិស្ថាននិងការរានដីយ៉ាងរហ័ស គឺជាចំណោទនៃកង្វះរពាក់។[2]



រូបលេខ១ គម្លោតរពាក់តាមវាលស្រែ (រដូវផ្លែរពាក់ទុំ)

---

[1] ក្រសួងសុខាភិបាល ២០១៧: ២៥៥

[2] សូមស្វែងយល់បន្ថែមលើតំណ៖ https://thmeythmey25.com/detail/90113

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## *អត្ថបទ៖ រពាក់និងប្រយោជន៍ក្នុងហត្ថកម្ម*

រពាក់ គឺជាពពួកវល្លិបន្លាស្ថិតក្នុងអំបូរផ្ដៅ ទាំងស្លឹក ទាំងដើម និងផ្លែមានរូបរាងដូចផ្ដៅ គ្រាន់តែរពាក់តូចជាងផ្ដៅ ហើយមានឈ្មោះវិទ្យាសាស្ត្រថា “*Calamus salicifolius Bec*” (រូបលេខ២២)។ ជាទូទៅដើមរពាក់មានទំហំប៉ុនចុងចង្កឹះ ឬតូចជាងនោះក៏មាន ហើយដើមស្រួយជាងផ្ដៅបន្តិច។ ផ្លែរពាក់ខ្ចីមានសម្បកពណ៌បៃតង មានរសជាតិចត់ខ្លាំង (រូបលេខ២៣)។ ឈានចូលដល់ដើមរដូវក្ដៅ (រវាងខែមីនា ឬមេសា) ផ្លែរពាក់ចាប់ផ្ដើមទុំ សម្បកប្រែពណ៌លឿងស្រាល សាច់ខាងក្នុងទៅជាពណ៌ត្នោត ឬខ្មៅ ហើយមានរសជាតិផ្អែមលាយចត់តិចៗ (រូបលេខ២៤)។ ប៉ុន្តែដើម្បីបន្ថយជាតិចត់ និងបង្កើនរសជាតិឱ្យត្រូវមាត់ គេអាចបកសម្បកចេញ ហើយក្រឡុកជាមួយអំបិលម្ទេសក៏បាន។ ក្នុងរដូវរពាក់ទុំនេះ អ្នកស្រុកតំបន់ខ្លះតែងបេះយកទៅចងចង្កោមលក់តាមផ្សារជាហូរហែ។



**រូបលេខ២២ ស្លឹករពាក់**



**រូបលេខ២៣ ផ្លែរពាក់ចាស់**



**រូបលេខ២៤ ផ្លែរពាក់ទុំ**

ដោយឡែក បើមើលតាមតម្រាក្បួនថ្នាំបុរាណ គេតែងយកឫសរពាក់ផ្សំនឹងឫសរុក្ខជាតិផ្សេងៗទៀត មានគុណប្រយោជន៍ព្យាបាលជំងឺប្រគ្រីវ។[3] មិនតែប៉ុណ្ណោះ នៅក្នុងឯកសារស្ដីពីរុក្ខជាតិឱសថកម្ពុជាឱ្យដឹងថា រពាក់ក៏មានគុណប្រយោជន៍ព្យាបាលរោគស្ត្រីក្រោយឆ្លងទន្លេ ជួយឱ្យបាយឆ្ងាញ់ ព្យាបាលលើសឈាម គ្រុនចាញ់ និងជំងឺថ្លើមដែរ។[4] ប៉ុន្តែយ៉ាងណាក៏ដោយ បើមើលចំពោះសារៈប្រយោជន៍រពាក់ក្នុងការប្រើប្រាស់ទូទៅ និង

[3] សូមអាន៖ ផែម គាត រឹទ្ធី និង មីស្លែល ឫទ្ធី អង់តែល្ម ២០០៣: ១១៤

[4] ក្រសួងសុខាភិបាល ២០០៨

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

ការងារហត្ថកម្មផ្សេងៗ គេឃើញមានច្រើនបែបណាស់ ពោលគឺអាស្រ័យដោយចំណេះច្នៃប្រើប្រាស់។ ចំណេះហត្ថកម្មផលិតសម្ភារៈទាំងនេះ អ្នកស្រុកតែងសង្កេត ស្វែងយល់ និងរៀនបន្តគ្នាក្នុងគ្រួសារ ឬក្នុងភូមិស្រុកជុំវិញគ្នាជាធម្មតា ហើយអ្វីដែលយើងគួរសង្កេត សូម្បីតែកិច្ចការហត្ថកម្មសិស្សសាលាជំនាន់មុន ក៏តែងឃើញគ្រូតម្រូវឱ្យសិស្សត្បាញ ឬធ្វើរបស់ប្រើប្រាស់ផ្សេងៗដែលគ្រួសាររបស់ខ្លួនចេះ យកទៅប្រើក្នុងសាលាដែរ។[5]

ជាការពិត រពាក់ច្រើនដុះតាមដំបូក ឬគម្ពោតព្រៃដីទំនេរក្បែរៗភូមិអ្នកស្រុក តែដោយកត្តាតម្រូវការខ្ពស់ អ្នកភូមិខ្លះត្រូវចំណាយពេលទៅកាប់រពាក់ពីតំបន់ឆ្ងាយយកមកប្រើប្រាស់។ បច្ចុប្បន្នមានករណីអ្នកស្រុកតំបន់អង្គរមួយភាគធំ ច្រើនតែឆ្លងទៅរករពាក់ដល់តំបន់ខ្លះនៃស្រុកប្រាសាទបាល័ង្ក ខេត្តកំពង់ធំ សម្រាប់យកទៅផ្គត់ផ្គង់ការត្បាញសម្ភារៈប្រើប្រាស់តម្រូវទីផ្សារ។[6] ចំពោះការងារបោចរពាក់នេះ ជាទូទៅគេច្រើនរកនៅខែប្រាំង ផុតពីការងារស្រែចម្ការ។ ជាធម្មតា គេតែងកាប់និងសម្អាតបន្ទានៅនឹងគុម្ពរពាក់ឱ្យស្រេច ទើបគេចងជាបាច់តូចៗល្មមជញ្ជូនយកទៅផ្ទះ (រូបលេខ៥-៦)។ លុះដឹកជញ្ជូនដល់ផ្ទះហើយ គេត្រូវរក្សាទុកបាច់រពាក់ទាំងនោះនៅក្នុងម្លប់ ដើម្បីបង្ការកុំឱ្យរពាក់ស្ងួតពេក នាំឱ្យស្រួយមិនអាចប្រើបាន។



រូបលេខ៥ ដូនចាស់ម្នាក់នៅជាយក្រុងខាងលិច រាជធានីភ្នំពេញ លីបាច់រពាក់សម្រាប់ធ្វើបង្កី



រូបលេខ៦ អ្នកភូមិរស់នៅឃុំល្វា ស្រុកពួក ខេត្តសៀមរាប ត្រឡប់មកពីកាប់រពាក់

[5] កម្មវិធីអប់រំក្នុងរវាងដើមទសវត្សរ៍ទី៩០ តែងមានម៉ោង "ហត្ថកម្ម" តម្រូវឱ្យសិស្សធ្វើវត្ថុប្រើប្រាស់ផ្សេងៗ ដោយដែសម្រាប់យកទៅដាក់ពិន្ទុ និងប្រើប្រាស់ក្នុងសាលា។

[6] សូមស្វែងយល់បន្ថែមលើតំណ៖ https://thmeythmey25.com/detail/90113

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ រពាក់និងប្រយោជន៍ក្នុងហត្ថកម្ម

ចំពោះសម្ភារៈប្រើប្រាស់ទាំងឡាយ ដែលកើតពីការត្បាញ ឬក្រងរពាក់មានច្រើនបែបច្រើនសណ្ឋានណាស់ ពោលគឺអាស្រ័យលើគំនិតបញ្ញារបស់អ្នកត្បាញចេះច្នៃបង្កើតឡើង។ មិនតែប៉ុណ្ណោះ រពាក់ក៏ប្រើជាផ្នែកខ្លះនៃសង្ហារិមដែរ ជាពិសេសគេអាចប្រើរពាក់ផ្សំជាមួយផ្ដៅ ឬស្សី ឬវល្លិថ្នឹងដូចជា កៅអី ឬសាឡុង។ លើសពីនេះក្នុងរយៈពេលចុងក្រោយ គេសង្កេតឃើញមានអង្គការខ្លះចុះប្រមូលផ្ដុំអ្នកភូមិជាក្រុម ហើយបង្ហាត់បង្រៀនគំរូ ឬទម្រង់វត្ថុប្រើប្រាស់ថ្មីៗជាច្រើនទៀតដែលអាចត្បាញ ឬក្រងចេញពីរពាក់ (រូបលេខ៧-៨)។ វត្ថុទាំងអស់នោះ គេដឹងថាខ្លះសម្រាប់លក់ដូរក្នុងស្រុក ហើយមួយចំនួនទៀតមានឈ្មួញដើរប្រមូលទិញនាំទៅលក់ក្រៅស្រុក។



*រូបលេខ៧-៨ សម្ភារៈប្រើប្រាស់ផ្សេងៗត្បាញពីរពាក់ (ប្រភព៖ ជីវៈចម្រុះនៃប្រទេសកម្ពុជា)*

ការប្រើប្រាស់វត្ថុផ្សេងៗត្បាញ ឬក្រងអំពីរពាក់ គេសង្កេតឃើញមានច្រើននៅតាមផ្ទះ ឬវត្តអារាមតាមតំបន់ស្រុកស្រែចម្ការ។ សម្ភារៈខ្លះ ជាវត្ថុដែលយើងសង្កេតឃើញអ្នកស្រុកប្រើប្រាស់តាំងពីដើមមកដូចជា កំប្រោង ត្រកដាក់ត្រី កញ្ជ្រែងដាក់នំបញ្ចុក បង្គី ឬឈ្នាងជញ្ជាត់ត្រី (ខ្លះធ្វើពីឬស្សី) ជាដើម។ ប៉ុន្តែវត្ថុខ្លះទៀត កើតពីការសង្កេត រៀនសូត្រ ច្នៃបន្ថែមឱ្យកើតជារូបរាងប្លែកៗតម្រូវតាមទីផ្សារ និងការរីកចម្រើនសព្វថ្ងៃដូចជា ប្រអប់ក្រដាសជូតមាត់ បំពង់ដាក់ប៊ិច គម្របសម្រាប់គ្របម្ហូបអាហារ កញ្ជ្រែងដាក់ចាន ឬកន្ទ្រកដាក់សម្លៀកបំពាក់។ ជាក់ស្ដែង កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះរដ្ឋបាលស្រុកបន្ទាយស្រី នៃខេត្តសៀមរាប បានច្នៃត្បាញធុងសំរាមអំពីរពាក់ ដែលជាផ្នែកមួយជួយដល់បរិស្ថាន និងការលើកតម្លៃសម្ភារៈហត្ថកម្មរបស់អ្នកស្រុក (រូបលេខ៩-១៧)។ លើសពីនេះ គេសម្គាល់ឃើញវត្ថុត្បាញពីរពាក់មានតម្លៃសមរម្យ និងប្រើប្រាស់បានយូរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៩-១៧ សម្ភារៈផ្សេងៗទៀតដែលត្បាញពីរពាក់និងការប្រើប្រាស់នៅទីនានា

សង្ខេបសេចក្តីមក រពាក់ជារុក្ខជាតិមានប្រយោជន៍ច្រើនក្នុងសង្គមខ្មែរ ជាពិសេសនៅក្នុងការងារហត្ថកម្ម ត្បាញ ឬក្រងជាវត្ថុប្រើប្រាស់ផ្សេងៗ និងលក់ដូរទៅក្នុងទីផ្សារជិតឆ្ងាយនានា។ ប៉ុន្តែបច្ចុប្បន្ន ការថយចុះព្រៃរពាក់ជាមូលហេតុធំនៃការឈានទៅបាត់បង់ការផ្ទេរចំណេះដឹងហត្ថកម្មបែបប្រពៃណីនៅក្នុងគ្រួសារ និងសហគមន៍ ស្របនឹងកំណើននៃវត្ថុប្រើប្រាស់ជំនួសដែលផលិតពីជ័រ និងលោហៈ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារពិគ្រោះ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០១៧, *បញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

ក្រសួងសុខាភិបាល

២០០៨, *រុក្ខជាតិឱសថកម្ពុជា*, មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្របុរាណ, ភ្នំពេញ

ផៃម គាត រីទ្ធី និង មីស្ហែល បូទ្ធី អង់តែល្ម

២០០៤, "អំពីវាន១ខ្សែ ក្រោមចំណងជើងថា "នេះត្នាំរ៉ាបក្បួនត្នាំមកែ់រោគទ្វ៉ា៤",
*សិក្សាចក្រ*, លេខ២៦,មជ្ឈមណ្ឌលខេរសិក្សា, ភ្នំពេញ

អរិយធម៌ខ្មែរ
KHMER CIVILIZATION